ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧៥ សរាច

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៤ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១

*-សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*

*-សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

*-សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្មួយៗ សិក្ខាកាម សិស្ស និស្សិត មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និយោជក ដៃគូអភិវឌ្ឍ និងបងប្អូនជនរួមជាតិទាំងអស់ជាទីស្រលាញ់រាប់អាន!*

ក្នុងនាមរាជរដ្ឋាភិបាល ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ក្នុងការចូលរួមអបអរសាទរជាមួយសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិក្ខាកាម សិស្ស និស្សិត មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និយោជក ដៃគូអភិវឌ្ឍ និងបងប្អូនជនរួមជាតិទាំងអស់ ក្នុងឱកាសដ៏មហោឡារិកនៃការប្រារព្ធ **ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៤** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ៦កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ក្រោមប្រធានបទ"TVET **ធ្វើឱ្យជំនាញកាន់តែប្រសើរ និងប្រាក់ចំណូលខ្ពស់**"។ ក្នុងស្មារតីបន្តអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដ៏កាចសាហាវ ការរៀបចំទិវាជាតិក្នុងឆ្នាំនេះ ត្រូវបានបន្តធ្វើក្នុងទម្រង់ជាយុទ្ធនាការតាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយ ដូចដែលបានរៀបចំនៅឆ្នាំ២០២០ កន្លងមកដែរ ក្នុងគោលបំណងដើម្បីបង្កើនការយល់ដឹងទូលំទូលាយទូទាំងប្រទេសអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅក្នុងការអភិវឌ្ឍជំនាញឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព សំដៅលើកកម្ពស់សមត្ថភាពរបស់ប្រជាពលរដ្ឋគ្រប់រូប ក្នុងការចាប់យកឱកាសការងារកាន់តែល្អ និងលើកស្ទួយកម្រិតជីវភាពកាន់តែប្រសើរឡើង។

កន្លងមក និងពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកការអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាអាទិភាពខ្ពស់បំផុតក្នុងគ្រប់ក្របខ័ណ្ឌគោលនយោបាយជាតិ ហើយបានធ្វើការវិនិយោគយ៉ាងសន្ធឹកសន្ធាប់លើវិស័យនេះ ដើម្បីខិតខំរត់តាមឱ្យទាន់មហិច្ឆតាក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម

និងការប្រែប្រួលយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា និងទីផ្សារការងារ ព្រមទាំងក្ដីរំពឹងកាន់តែខ្ពស់របស់ប្រជាពលរដ្ឋក្នុងការមានការងារធ្វើល្អ និងកម្រិតជីវភាពកាន់តែប្រសើរឡើង។ ជាក់ស្ដែងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នេះ បានផ្ដល់អាទិភាពខ្ពស់ជាងគេបំផុតលើការអភិវឌ្ឍធនធានមនុស្សតាមរយៈការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សំដៅកសាងបាននូវកម្លាំងពលកម្មដែលមានជំនាញច្បាស់លាស់ គំនិតច្នៃប្រឌិត និងភាពប្រកួតប្រជែងខ្ពស់ និងធានាឱ្យបាននូវ ***"យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត"*** ។ ដើម្បីសម្រេចបានគោលដៅទាំងនេះ រាជរដ្ឋាភិបាលបាននិងកំពុងបន្តខិតខំជំរុញការអនុវត្តគោលនយោបាយជាតិស្ដីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ និងគោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ព្រមទាំងបានខិតខំធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ផ្ដោតអាទិភាពខ្ពស់លើការលើកកម្ពស់គុណភាពគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ដោយពង្រីកការវិនិយោគលើការកសាងហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែករឹងរួមមាន អគារសិក្សា រោងជាង បន្ទប់ពិសោធន៍ មជ្ឈមណ្ឌលស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ មូលដ្ឋានសម្ភារនិងបរិក្ខារ និងផ្នែកទន់ រួមមានប្រព័ន្ធធានាគុណភាពនិងអភិបាលកិច្ច គុណភាព សមត្ថភាពគ្រូ កញ្ចប់ស្តង់ដាបណ្ដុះបណ្ដាលនិងប្រព័ន្ធវាយតម្លៃផ្អែកលើសមត្ថភាព ការទំនាក់ទំនងជាមួយឧស្សាហកម្ម និងការចុះកម្មសិក្សាអនុវត្តផ្ទាល់នៅកន្លែងធ្វើការ ដែលបច្ចុប្បន្ននេះមានគ្រឹះស្ថានចំនួន ២៥ ត្រូវបានទទួលស្គាល់គុណភាពពីអង្គការស្តង់ដាអន្តរជាតិ (ISO)។

ចាប់តាំងពីឆ្នាំ២០២០ មក គ្រឹះស្ថានសិក្សានៅទូទាំងប្រទេសទាំងសាធារណៈ ឯកជន និងអង្គការសមាគម ត្រូវបានផ្អាកដំណើរការសិក្សា និងសកម្មភាពនានាជាបន្តបន្ទាប់ ទៅតាមដំណាក់កាលនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។ កត្តានេះ បានធ្វើឱ្យមានការផ្លាស់ប្ដូររបៀបនៃការបង្រៀន និងរៀននៅក្នុងថ្នាក់រៀន មកធ្វើការរៀបចំការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញជំនួសវិញ។ នៅគ្រប់គ្រឹះស្ថានសិក្សានានា បាននិងកំពុងខិតខំអនុវត្តកម្មវិធីបណ្ដុះបណ្ដាលពីចម្ងាយ ឬតាមអនឡាញជូនដល់សិក្ខាកាម សិស្ស និស្សិត ដើម្បីធានាបាននូវនិរន្តរភាពនៃការទទួលបានការអប់រំ និងបណ្ដុះបណ្ដាល ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ការផលិតវីដេអូនិងឯកសារនានាសម្រាប់ការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញ និងការប្រើប្រាស់បណ្ដាញសង្គមនានាសម្រាប់ការទំនាក់ទំនង។ ថ្មីៗនេះ តាមរយៈក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បាននិងកំពុងដាក់ឱ្យដំណើរការប្រព័ន្ធជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈពីចម្ងាយ ឬតាមអនឡាញ ព្រមទាំងបំពាក់មូលដ្ឋានឧបករណ៍បច្ចេកវិទ្យាព័ត៌មាន ក៏ដូចជាការអភិវឌ្ឍនិងកែលម្អកម្មវិធីសិក្សា និងបំប៉នសមត្ថភាពគ្រូបច្ចេកទេសនូវវិធីសាស្ត្របង្រៀនបែបគន្លងថ្មីសម្រាប់គាំទ្រដល់ការបង្រៀន និងរៀនពីចម្ងាយ ឬតាមអនឡាញរបស់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិក្ខាកាម សិស្ស និស្សិត នៅតាមគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ។

កម្មវិធីបណ្ដុះបណ្ដាលត្រូវបានរៀបចំឱ្យមានភាពបត់បែនស្របតាមស្ថានភាពជាក់ស្ដែងរបស់ប្រជាពលរដ្ឋ ក្នុងទម្រង់ជារយៈពេលខ្លី និងរយៈពេលវែង ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ហើយអាចធ្វើឡើងនៅ

តាមគ្រឹះស្ថានសិក្សា សហគ្រាស សហគមន៍ និងដោយចល័ត។ ដើម្បីផ្តល់លទ្ធភាពទទួលបានការបណ្តុះបណ្តាលប្រកបដោយសមធម៌ រាជរដ្ឋាភិបាលបានពង្រីកការផ្តល់អាហារូបករណ៍កាន់តែច្រើនឡើងសម្រាប់យុវជនដែលបានបោះបង់ការសិក្សា ប្រជាពលរដ្ឋក្រីក្រ ស្ត្រី ជនពិការ កុមារកំព្រា ជនជាតិដើមភាគតិច ជនងាយរងគ្រោះ ជាលទ្ធផលរយៈពេល៥ឆ្នាំ ចុងក្រោយនេះ មានសិក្ខាកាម សិស្ស និស្សិត និងកម្មករនិយោជិតជាង ២០ម៉ឺននាក់ បានទទួលការបណ្តុះបណ្តាល និងបញ្ចប់ការសិក្សាដោយជោគជ័យ ក្នុងការទទួលបានជំនាញថ្មី និងលើកកម្ពស់ជំនាញរបស់ខ្លួន ហើយបានចាប់យកឱកាសការងារល្អៗ និងបង្កើតមុខរបរដោយខ្លួនឯង និងបានបង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងជួយលើកស្ទួយសេដ្ឋកិច្ចជាតិបានយ៉ាងច្រើន។

លើសពីនេះ កម្មករនិយោជិតដែលកំពុងត្រូវបានព្យួរការងារ ឬបាត់បង់ការងារដោយសារវិបត្តិជំងឺកូវីដ-១៩ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំឱ្យមានវគ្គបណ្តុះបណ្តាលពិសេសមួយដែលមានភាពបត់បែន និងផ្តោតលើគុណភាពក្រោយពេលបញ្ចប់ការសិក្សាលើកម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ព្រមទាំងបានផ្តល់នូវប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលសិក្សាដោយសិក្ខាកាមម្នាក់ទទួលបាន ២០ម៉ឺនរៀល ក្នុង ១ខែ ដើម្បីផ្តល់ឱកាសឱ្យពួកគាត់ទទួលបាននូវជំនាញមួយច្បាស់លាស់សម្រាប់ចាប់យកការងារថ្មីនៅក្នុងទីផ្សារការងារ ដែលកំពុងមានតម្រូវការខ្ពស់នាពេលបច្ចុប្បន្ន និងទៅអនាគត ហើយអាចប្រកបមុខរបរដោយខ្លួនឯងបាន និងបានធ្វើការបណ្តុះបណ្តាលជំនាញទន់ជូនដល់កម្មករនិយោជិតនៅតាមបណ្តារោងចក្រ សហគ្រាស ចំនួន ៦៨ ០០០នាក់ផងដែរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងស្ថាប័នពាក់ព័ន្ធនានា ក្នុងការខិតខំអនុវត្តដោយជោគជ័យនូវគោលនយោបាយអាទិភាពនិងការកែទម្រង់ស៊ីជម្រៅ ដែលរាជរដ្ឋាភិបាលបានដាក់ចេញសម្រាប់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ ខ្ញុំក៏សូមយកឱកាសនេះ អំពាវនាវដល់គ្រប់តួអង្គពាក់ព័ន្ធសូមបន្តចូលរួម៖

១- បន្តការគាំទ្រក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ ក្នុងការអភិវឌ្ឍធនធានមនុស្សពោរពេញដោយសមត្ថភាពជំនាញ ដោយក្នុងដំណាក់កាលនេះ គ្រប់គ្រឹះស្ថានសិក្សាទាំងអស់ ត្រូវបន្តរៀបចំកម្មវិធីបណ្តុះបណ្តាលពីចម្ងាយ ឬតាមអនឡាញ និងបត់បែនតាមស្ថានភាពជាក់ស្តែង។

២- បន្តជំរុញលើកទឹកចិត្ត និងបង្កើនការចុះឈ្មោះចូលរៀនជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីឱ្យមានចំណេះដឹង ជំនាញច្បាស់លាស់ ឥរិយាបថការងារ និងសីលធម៌វិជ្ជាជីវៈល្អ ដូចដែលប្រធានបទនៃទិវាជាតិនេះបានលើកឡើង "**TVET ធ្វើឱ្យជំនាញកាន់តែប្រសើរ និងប្រាក់ចំណូលខ្ពស់**"។

៣- គ្រប់ស្ថានីយ៍វិទ្យុ ទូរទស្សន៍របស់រដ្ឋ និងឯកជន ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយនានា សូមបន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីបង្កើនការយល់ដឹងនូវសារៈសំខាន់នៃវិស័យនេះជូនសាធារណជន។

៤- ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិក្ខាកាម សិស្ស និស្សិត មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និយោជក ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងបងប្អូនជនរួមជាតិទាំងអស់ ចូលរួមសហការផ្សព្វផ្សាយទិវាជាតិអប់រំបណ្តុះបណ្តាល

បច្ចេកទេស និងវិជ្ជាជីវៈ លើកទី៤ ឆ្នាំ២០២១ ក្រោមប្រធានបទ "TVET **ធ្វើឱ្យជំនាញកាន់តែប្រសើរ និងប្រាក់ចំណូលខ្ពស់**" នេះ ឱ្យបានផុលផុសឱឡារិកអធិកអធមទូទាំងប្រទេសតាមប្រព័ន្ធផ្សព្វផ្សាយនានា។

ជាទីបញ្ចប់ ជាមួយនឹងឱកាសនៃការប្រារព្ធទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរនិងប្រគេនពរព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងជូនពរចំពោះ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិក្ខាកាម សិស្ស និស្សិត និងបងប្អូនជនរួមជាតិទាំងអស់ទូទាំងប្រទេស សូមចៀសផុតពីជំងឺកូវីដ-១៩ និងសូមប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ព្រហស្បតិ៍ ៥ កើត ខែ ពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**